# សេចក្តីថ្លែងការណ៍រួមរបស់សហជីព សមាគម និងអង្គការសង្គមស៊ីវិល
# អំពីតម្រូវការអាទិភាពរបស់ស្ត្រីកម្មករនិយោជិត និងកសិករ ក្នុងកំឡុងវិបត្តិកូវីដ១៩
# និងសំណើសុំអន្តរាគមបន្ទាន់ ពីសំណាក់រាជរដ្ឋាភិបាល និងក្រុមធុរៈកិច្ចក្នុងវិស័យឯកជន

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២០

កាលពីឆ្នាំ១៩៩១ស្ត្រីមួយក្រុមបានរួបរួមគ្នារៀបចំ "យុទ្ធនាការ១៦ថ្ងៃនៃភាពសកម្មនិយមដើម្បីលុបបំបាត់អំពើហិង្សាផ្អែកលើយេនឌ័រ" ដែលធ្វើឡើងចាប់ពីថ្ងៃទី២៥ខែវិច្ឆិកាហូតដល់ថ្ងៃទី១០ខែធ្នូ ក្នុងគោលបំណងអំពាវនាវឲ្យមានការចាត់វិធានការទប់ស្កាត់ និងលុបបំបាត់រាល់ទម្រង់នៃអំពើហិង្សាប្រឆាំងស្ត្រីនិងក្មេងស្រី នៅថ្នាក់អន្តរជាតិ និងថ្នាក់ជាតិ។ យុទ្ធនាការនេះបានបន្តធ្វើឡើងជារៀងរាល់ឆ្នាំរហូតមកដល់បច្ចុប្បន្ននេះ និងមានការចូលរួមពីសំណាក់ទីភ្នាក់ងារ អង្គការសហប្រជាជាតិ ភ្នាក់ងាររដ្ឋាភិបាល ក្រុមសកម្មជនស្ត្រីនិយម សហជីព និងអង្គការសង្គមស៊ីវិល ដែលបាននឹងកំពុងបំពេញបេសកកម្មដើម្បីលើកកម្ពស់សិទ្ធិស្ត្រី និងសមភាពយេនឌ័រស្ថិតក្នុងប្រទេសចំនួន១៨៧។ នៅក្នុងឱកាសយុទ្ធនាការ ១៦ថ្ងៃឆ្នាំនេះ យើងខ្ញុំជាសហជីព សមាគម និងអង្គការសង្គមស៊ីវិលចំនួន **៩ស្ថាប័ន** ដែលកំពុងបំពេញការងារនៅក្នុងព្រះរាជាណាចក្រកម្ពុជា សូមលើកយក**បញ្ហាប្រឈម** និង**តម្រូវការអាទិភាពរបស់ស្ត្រីកសិករ និងកម្មករនិយោជិត ក្នុងកំឡុងវិបត្តិសកលកូវីដ១៩** មកបង្ហាញរាជរដ្ឋាភិបាលក្រុមធុរៈកិច្ចក្នុងវិស័យឯកជន និងភ្នាក់ងារអភិវឌ្ឍន៍នានាជាព័ត៌មាន និងស្នើចាត់វិធានការបន្ទាន់ដើម្បីឆ្លើយតបតម្រូវការទាំងនោះ។

ជំងឺរាតត្បាតសកលកូវីដ១៩ បានបង្កផលប៉ះពាល់ដល់សុខមាលភាពផ្លូវកាយ ផ្លូវចិត្ត និងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋគ្រប់រូប និងបានធ្វើឲ្យសេដ្ឋកិច្ចជាតិធ្លាក់ចុះ និងដើរថយក្រោយ។ ស្ត្រីកម្មករនិយោជិតដែលកំពុងប្រកបការងារ នៅក្នុងវិស័យសេដ្ឋកិច្ចក្នុង និងក្រៅប្រព័ន្ធជាច្រើនម៉ឺននាក់ត្រូវបានព្យួរការងារ ឬបាត់បង់ការងារទាំងស្រុង។ កសិករ និង អ្នកលក់ដូរតាមដងផ្លូវត្រូវខាតបង់ប្រាក់ចំណូល ទន្ទឹមនេះដែរស្ថានភាពនៃអំពើហិង្សាផ្អែកលើយេនឌ័រក៏អាចមានការកើនឡើងមកលើស្ត្រី និងក្មេងស្រីនៅក្នុងកំឡុងពេលរីករាលដាលនៃជំងឺកូវីដ១៩នេះដែរ។ យើងខ្ញុំទទួលស្គាល់ នូវទុក្ខលំបាកនិងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩ និងការខិតខំទប់ស្កាត់កុំឲ្យសេដ្ឋកិច្ចជាតិដួលរលំ តាមរយៈការដាក់ចេញនូវវិធានការឆ្លើយតបចំពោះការខាតបង់ផ្នែកសេដ្ឋកិច្ចរបស់វិស័យឯកជន។

យើងខ្ញុំក៏ទទួលស្គាល់ផងដែរនូវការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលទៅលើកម្មករក្នុងវិស័យវាយនភ័ណ្ឌកាត់ដេរ

និងដេរស្បែកជើង និងវិស័យទេសចរណ៍តាមរយៈការផ្តល់នូវប្រាក់ឧបត្ថម្ភចំនួន៤០ដុល្លារ និងការចែកនូវស្បៀង និងសម្ភារៈការពារកូវីដ១៩ដល់ គ្រួសារក្រីក្រមួយចំនួន។

យើងខ្ញុំសូមយកឱកាសយុទ្ធនាការ១៦ថ្ងៃដើម្បីបង្ហាញជូនរដ្ឋាភិបាលឱ្យឃើញថា គោលនយោបាយឆ្លើយតបរបស់រាជរដ្ឋាភិបាលក្នុងកំឡុងវិបត្តិកូវីដ១៩នេះ នៅមានកង្វះចន្លោះដោយមានស្ត្រីកម្មករនៅក្នុងវិស័យសេដ្ឋកិច្ចក្នុង និងក្រៅប្រព័ន្ធជាច្រើននាក់ទៀត រួមទាំងស្ត្រីកសិករខ្នាតតូចដែលជាក្រុមអ្នកដែលរងផលប៉ះពាល់ធ្ងន់ធ្ងរជាងគេនៅក្នុងកំឡុងពេលនេះមិនទាន់បានរាប់បញ្ចូលនៅក្នុងវិធានការដោះស្រាយ។ ដោយសារតែជីវភាពប្រចាំថ្ងៃរបស់ពួកគាត់ និងក្រុមគ្រួសារត្រូវពឹងអាស្រ័យលើចំណូលជាប្រចាំថ្ងៃនិងប្រចាំខែរបស់ពួកគាត់ នៅពេលដែលពួកគាត់បាត់បង់ ឬត្រូវព្យួរការងារជីវភាពរបស់គាត់ត្រូវធ្លាក់ចុះក្រោមបន្ទាត់នៃភាពក្រីក្រ ហើយស្ថានភាពកាន់តែរីករវដោយសារតែបំណុលដែលគាត់ជំពាក់គ្រឹះស្ថានហិរញ្ញវត្ថុឯកជននិងឬម្ចាស់បំណុលឯកជន។
ស្ត្រីកសិករនិងកម្មករនិយោជិតទាំងវិស័យសេដ្ឋកិច្ចក្នុង និងក្រៅប្រព័ន្ធគឺជា ឆ្អឹងខ្នងសេដ្ឋកិច្ចជាតិ នៅពេលរាជរដ្ឋាភិបាល និងធុរៈកិច្ចជនខកខានមិនបានឆ្លើយតបតម្រូវការអាទិភាពរបស់ពួកគាត់ ហាក់មានន័យថាពួកគាត់មិនត្រូវបានយកចិត្តទុកដាក់ ឬ ត្រូវបានទុកចោលនៅក្នុងគ្រាដ៏លំបាកនេះ។

ដូច្នេះយើងខ្ញុំ **ស្នើដល់រាជរដ្ឋាភិបាល និងក្រុមធុរៈកិច្ចក្នុងវិស័យឯកជន បង្កើនការវិនិយោគលើប្រព័ន្ធកិច្ចគាំពារសង្គម និងចាត់វិធានការឆ្លើយតបលើតម្រូវការអាទិភាពចំនួន៧ចំណុចរបស់ស្ត្រីកសិករនិងកម្មករនិយោជិត ក្នុងនិងក្រៅប្រព័ន្ធ** ដូចខាងក្រោមនេះដើម្បីធានាថាគ្មានពលរដ្ឋណាម្នាក់ត្រូវបានទុកចោល៖

១. ស្នើរដ្ឋាភិបាលផ្តល់ប្រាក់ឧបត្ថម្ភប្រចាំខែចំនួន៤០ដុល្លាក្នុងកំឡុងពេលរីករាលដាលនៃជំងឺកូវីដ១៩ ដល់កម្មករនិយោជិតគ្រប់វិស័យទាំងក្នុងនិងក្រៅប្រព័ន្ធ។

២. ស្នើអាជ្ញាធរមូលដ្ឋាន រួមទាំងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសុខាភិបាល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រួលលក្ខខណ្ឌចុះបញ្ជីបេឡាបេបសន្តិសុខសង្គមដើម្បីទទួលបានប័ណ្ណមូលនិធិសមធម៌សុខាភិបាលសម្រាប់កម្មករក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងកសិករខ្នាតតូច ជាពិសេសសូមធានាថា កម្មករស្ត្រីមានផ្ទៃពោះអាចប្រើសេវាសុខាភិបាលដោយមិនអស់ថ្លៃសេវា និងទទួលបានប្រាក់ឧបត្ថម្ភដើម្បីសម្រួលជីវភាពប្រចាំថ្ងៃបន្ថែមទៀត។

៣. ស្នើរដ្ឋាភិបាល និងក្រុមនិយោជក ចាត់វិធានការទប់ស្កាត់និងលុបបំបាត់អំពើបៀតបៀនផ្លូវភេទ និងការរើសអើងផ្អែកលើយេនឌ័រនៅក្នុងពិភពការងារចាត់នីតិវិធីដើម្បីផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពី ការលុបបំបាត់អំពើហិង្សា និងការយាយីផ្អែកលើយេនឌ័រក្នុងពិភពការងាររបស់អង្គការអន្តរជាតិខាងការងារ(ILO.C 190) ។

៤. ស្នើរដ្ឋាភិបាលរឹតបណ្តឹង និងពង្រឹងការអនុវត្តច្បាប់ដើម្បីបញ្ឈប់អំពើហិង្សាបង្កឡើងដោយដៃគូស្និទ្ធស្នាល និងអំពើហិង្សាផ្អែកលើយេនឌ័រគ្រប់រូបភាព បង្កើនការផ្តល់សេវាឆ្លើយតបជាពិសេសក្នុងកំឡុងវិបត្តិកូវីដ១៩ ដែលផ្តោតការយកចិត្តទុកដាក់ដោះស្រាយសុខុមាលភាពផ្លូវកាយ ផ្លូវចិត្ត និងធានាថាជនរងគ្រោះទទួលបានយុត្តិធម៌។

៥. ស្នើរដ្ឋាភិបាលការពារសិទ្ធិដីធ្លីកសិករដោយចាត់វិធានការបន្ទាន់ដើម្បីដោះស្រាយជម្លោះដីធ្លីដែលអូសបន្លាយរ៉ាំរ៉ៃ និងបញ្ឈប់នូវការប្រើប្រាស់ប្រព័ន្ធតុលាការដើម្បីដាក់សម្ពាធឲ្យកសិករបញ្ឈប់សកម្មភាពតវ៉ាអំពីជម្លោះដីធ្លី។

៦. ស្នើរដ្ឋាភិបាលដាក់បញ្ចូលក្រុមកសិករទៅក្នុងច្បាប់ស្តីពីកិច្ចគាំពារសង្គម។

៧. ស្នើក្រុមហ៊ុនបញ្ជារទិញ និងអ្នកផ្គត់ផ្គង់រៀបចំថវិកាសង្គ្រោះបន្ទាន់តាមរយៈការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែម ចំនួន ៧៦ (ចិតសិបប្រាំមួយ) ដុល្លា ជារៀងរាល់ខែពីលើប្រាក់ឧបត្ថម្ភប្រចាំខែចំនួន ៤០(សែសិប) ដុល្លារ ដែលរដ្ឋាភិបាលបានផ្តល់ឲ្យកម្មករនិយោជិតក្នុងវិស័យវាយនភ័ណ្ឌកាត់ដេរ និងដេរស្បែកជើងដែលត្រូវបានព្យួរពីការងារ។

**សេចក្តីថ្លែងការរួមនេះចូលរួមគាំទ្រដោយ៖**

១. សហពន្ធ័សហជីពកម្មករចំណីអាហារ និងសេវាកម្មកម្ពុជា (CFSWF)

២. សហពន្ធ័សហជីពកម្ពុជា (CATU)

៣. សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA)

៤. អង្គការមជ្ឈមណ្ឌលសម្ពន្ធ័ភាពការងារ និងសិទ្ធិមនុស្ស (CENTRAL)

៥. សមាគមសម្ពន្ធ័សហគមន៍កសិករកម្ពុជា (CCFC)

៦. សហព័ន្ធសហជីពកម្មករសំណង់ និងព្រៃឈើកម្ពុជា (BWTUC)

៧. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR)

៨. អង្គការក្លាហាន (Klahaan)

៩. អង្គការអាកសិនអេតកម្ពុជា (ActionAid Cambodia)

**សម្រាប់ព័ត៌មានបន្ថែម៖**

អ្នកស្រី អ៊ូ ទេពផល្លីន ០១១ ៩៨៤ ៨៨៣ ប្រធានសហពន្ធ័សហជីពកម្មករចំណីអាហារ និងសេវាកម្ម កម្ពុជា

អ្នកស្រី ចក់ សុភាព ០១១ ៩៤៣ ២១៣ នាយិកាប្រតិបត្តិនៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

អ្នកស្រី យ៉ាង សុភ័ណ្ឌ ០១២ ៨៨០ ០៣៩ ប្រធានសហព័ន្ធសហជីពកម្ពុជា

អ្នកស្រី ឆន សុខា ០៩៣ ៥៥៦ ៦៣៤ ប្រធានកម្មវិធីចងក្រងនៃមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារនិងសិទ្ធមនុស្ស

អ្នកស្រី បុណ្យ រចនា ០៨៩ ៤៧៦ ១៤៦ សហស្ថាបនិក និង នាយិកា នៃអង្គការក្លាហាន

អ្នកស្រី រិន ម៉ាក់ទីន ០១៥ ៤៥៦ ៧៣៨ អ្នកសម្របសម្រួលគម្រោង សហព័ន្ធសហជីពកម្មករសំណង់ និងព្រៃឈើកម្ពុជា

អ្នកស្រី វ៉ុន សម្ផស្ស ០១៦ ៤៥៨ ៧២១ អគ្គលេខាធិការរង នៃសមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ

អ្នកស្រី កែ ចាន់រ៉ា ០៧៧ ៥៥៣ ២១១ អគ្គលេខាធិការនៃសមាគមសម្ពន្ធ័សហគមន៍កសិករកម្ពុជា

អ្នកស្រី អ៊ូ សុភារី ០១២ ៦២១ ៨២២ មន្ត្រីសម្របសម្រួលកម្មវិធីយុទ្ធនាការ អង្គការអាក់សិនអេត

*សូមភ្ជាប់ជូននូវព័ត៌មានបន្ថែមខាងក្រោម

## ព័តមានបន្ថែម

កម្មករស្ត្រីក្នុងវិស័យសេវាកម្សាន្ត( ខារ៉ាអូខេនិងម៉ាស្សា )៖

យោងតាមការស្ទង់មតិរបស់អង្គការអោក់សិនអេតអំពីផលប៉ះពាល់នៃកូវីដ១៩លើស្ថានភាពសេដ្ឋកិច្ច និងសង្គមរបស់កម្មករក្រៅប្រព័ន្ធ ចំនួន ៣៨៤នាក់ ដែលក្នុងនោះមានកម្មករស្ត្រីក្នុងវិស័យសេវាកម្សាន្តដែរនោះ បានរកឃើញថា៖

- ២៧% នៃកម្មករស្ត្រីសេវាកម្សាន្ត រកចំណូលបានក្រោម $១.៩០ ក្នុងមួយថ្ងៃ ក្នុងកំឡុងពេលកូវីដ១៩
- មាន ១/៣ គ្រួសារកម្មករសេវាកម្សាន្ត ធ្លាក់ក្នុងស្ថានភាពដែលមិនមានអាហារហូបគ្រប់គ្រាន់
- មានតែ ១/១០ គ្រួសារកម្មករសេវាកម្សាន្តទេ ដែលបានទទួលការឧបត្ថម្ភជាអាហារ ថវិកា ឬម៉ាស់និងអាកុល
- ៧៤% នៃកម្មករសេវាកម្សាន្តមិនមានប័ណ្ណបសស ឬ ប័ណ្ណក្រីក្រ ឬប័ណ្ណមូលនិធិសមធម៌សុខាភិបាលទេ
- កម្មករសេវាកម្សាន្តមិនត្រូវបានរាប់បញ្ចូលទៅក្នុងប្រ ព័ន្ធកិច្ចគាំពារសង្គមដើម្បីទទួលបានប្រាក់ឧបត្ថម្ភន៍ ពីរាជរដ្ឋាភិបាលអំឡុងពេលព្យួរការងារដោយសារវិបត្តិកូវីដ១៩ ដូចវិស័យកាត់ដេរនិងវិស័យទេសចរណ៍ទេ

កម្មករស្ត្រីក្នុងវិស័យទេសចរណ៍ សណ្ឋាគារ និងកាស៊ីណូ៖

- បុគ្គលិកធ្វើការផ្នែកកាស៊ីណូជាង ៤០០០ នាក់នៅណាហ្គាវើលដ៏ និងបុគ្គលិករាប់ម៉ឺននាក់នៅកាស៊ីណូផ្សេងទៀតទូទាំងប្រទេស មិនត្រូវបានរាប់បញ្ចូលទៅក្នុងប្រព័ន្ធកិច្ចគាំពារសង្គមរបស់រាជរដ្ឋាភិបាល ដើម្បីទទួលបាននូវប្រាក់ឧបត្ថម្ភក្នុងអំឡុងពេលព្យួរការងារដោយសារវិបត្តិកូវីដ១៩ឡើយ។
- បុគ្គលិកបំរើការនៅផ្នែកសណ្ឋាគារណាហ្គាវើលដ៏ជាង ៤០០០នាក់ បានទទួលប្រាក់ឧបត្ថម្ភពីរដ្ឋាភិបាល តែពីរខែប៉ុណ្ណោះ ខណៈពួកគាត់ត្រូវបានព្យួរការងារតាំងពីខែមេសារហូតដល់បច្ចុប្បន្ន។
- បុគ្គលិកកាស៊ីណូរាប់ពាន់នាក់នៅទូទាំងប្រទេសត្រូវបាត់បង់ការងារទាំងស្រុងដោយនិយោជកមិនអនុញ្ញាតឱ្យចូលធ្វើការវិញនៅពេលរដ្ឋាភិបាលប្រកាសឱ្យបើកដំណើរការកាស៊ីណូវិញទូទាំងប្រទេសដោយសារព្រំដែននៅបន្តបិទ ដដែល។
- បុគ្គលិកស្ត្រីរាប់រយនាក់នៅណាហ្គាវើលដ៏ត្រូវបានកាត់បន្ថយអត្ថប្រយោជន៍ពី បសស សម្រាប់លំហែមាតុភាពជិត៤០%នៃប្រាក់ដែលត្រូវទទួលបាន។

កម្មករក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ (យោងតាមការស្ទង់មតិរបស់សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ បានសម្ភាសន៍កម្មករក្រៅប្រព័ន្ធដែលជាសមាជិកចំនួន៧០០នាក់ ក្នុងនោះមានអ្នករត់ម៉ូតូកង់បីចំនួន២០០នាក់ អ្នកធ្វើការតាមផ្ទះចំនួន៣០០នាក់ និងអ្នកលក់ដូរតាមផ្លូវចំនួន២០០នាក់ ដើម្បីស្វែងយល់ពីទុក្ខលំបាកនិងតម្រូវការចាំបាច់របស់កម្មករដែលរងផលប៉ះពាល់ដោយសារវិបត្តិកូវីដ១៩។)៖

- ប្រាក់ចំណូលរបស់កម្មករធ្លាក់ចុះរហូតដល់៥០% ក្នុងកំឡុងពេលកូវីដ១៩
- មានកម្មករប្រមាណ ៣៤% បានបាត់បង់ការងារនិងកំពុងរកការងារថ្មីធ្វើ
- កម្មករមិនមានលទ្ធភាពទិញសំភារៈការពារពីការឆ្លងកូវីដ ដូចជាម៉ាស់ និងជែលលាងដៃជាដើម។
- ៦១% នៃកម្មករ មិនមានលទ្ធភាពបង់ការប្រាក់ឬសងបំណុលធនាគារឬមីក្រូហិរញ្ញវត្ថុ
- អ្វីដែលកម្មករបារម្ភបំផុតពីវិបត្តិកូវីដគឺ ការបាត់បង់ប្រាក់ចំណូល បាត់បង់ការងារ កូនត្រូវបោះបង់ចោលការសិក្សា និងមិនអាចទទួលបានសេវាសុខភាពដែលមានគុណភាព
- ជាង៤,០០០នាក់/១៥,០០០នាក់ នៃសមាជិកសមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ ទទួលបាននូវប័ណ្ណមូលនិធិសមធម៌សុខាភិបាល។ ប៉ុន្តែបច្ចុប្បន្ន និតិវិធីនៃការចុះបញ្ជីមានភាពរាំងស្ទះ ដោយសាររាជរដ្ឋាភិបាលតម្រូវឱ្យមានលិខិតបញ្ជាក់ពីមុខរបរ និងកន្លែងស្នាក់នៅរបស់កម្មករ តែរាជរដ្ឋាភិបាលមិនទាន់មានយន្តការច្បាស់លាស់ពីភ្នាក់ងារដែលត្រូវទទួលបន្ទុកចេញលិខិតបញ្ជាក់ទាំងនេះព្រមទាំងទម្រង់នៃលិខិតបញ្ជាក់ផងដែរ ហើយ អ្នកប្រកបមុខរបរក្រៅប្រព័ន្ធភាគច្រើនជាអ្នកចំណាកស្រុកមកពីខេត្តនានា ដោយជួលបន្ទប់ស្នាក់នៅ ឬជួលដីបោះតង់ស្នាក់នៅបណ្ដោះអាសន្ន។

កម្មករក្នុងវិស័យវាយនភ័ណ្ឌកាត់ដេរ និងដេរស្បែកជើង៖ (យោងតាមការស្ទង់មតិរបស់ សហពន្ធ័សហជីពកម្ពុជា មជ្ឈមណ្ឌលសម្ព័នភាព ការងារ និងសិទ្ធិមនុស្ស និងសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស)

- ៦៣% នៃកម្មករកាត់ដេរជាប់កម្ចីឥណទាន ហើយភាគច្រើនខ្ចីពីកន្លែងមួយទៅសងកន្លែងមួយទៀត
- កម្មករកាត់ដេរប្រមាណ ១៥ ម៉ឺននាក់ បានបាត់បង់ការងារក្នុងកំឡុងពេលកូវីដ យោងតាមសេចក្ដីថ្លែងការណ៍របស់សមាគមរោងចក្រកាត់ដេរកម្ពុជា

- កម្មករកាត់ដេរបាត់បង់អត្ថប្រយោជន៍ដោយសាមានការបង្កើតសេចក្តីណែនាំនិងសេចក្តីជូនដំណឹងផ្ទុយពីច្បាប់។ (សេចក្តីជូនដំណឹងលេខ ០១៨/២០ ស្តីពីការពន្យាពេលក្នុងការបើករំលឹកប្រាក់បំណាច់អតីតភាពការងារដែលមានមុនឆ្នាំ ២០១៩ និងប្រាក់អតីតភាពការងារថ្មីក្នុងឆ្នាំ២០២០)
- ការផ្តល់ប្រាក់ឧបត្ថម្ភតែ៧០ដុល្លាក្នុងមួយខែ នៅពេលដែលកម្មករត្រូវបានថៅកែព្យួរកិច្ចសន្យាការងារលើសពីពីរខែធ្វើអោយប៉ះពាល់ដល់ជីវភាពរស់នៅប្រចាំថ្ងៃរបស់កម្មករ

ពលករចំណាកស្រុក៖ (យោងតាមការស្ទង់មតិរបស់មជ្ឈមណ្ឌលសម្ព័នភាពការងារ និងសិទ្ធិមនុស្ស)

- ៦៨% នៃពលករចំណាកស្រុកកំពុងតែជាប់បំណុលធនាគារ
- ពលករចំណាកស្រុកតែ៣៨%ប៉ុណ្ណោះដែលមានបណ្ណក្រីក្រ
- ៦៨% នៃពលករចំណាកស្រុកដែលបានត្រឡប់មកស្រុកកំណើតវិញកំឡុងពេលវិបត្តិកូវីដ ១៩ នៅតែចង់ត្រឡប់ទៅធ្វើការចំណាកស្រុកនៅក្រៅប្រទេសវិញ។
- ៦៥%នៃពលករចំណាកស្រុកដែលបានត្រលប់មកកម្ពុជា មិនបានទទួលជំនួយឧបត្ថម្ភពីរាជរដ្ឋាភិបាលនោះទេ។

កម្មករសំណង់៖ (យោងតាមការស្ទង់មតិរបស់មជ្ឈមណ្ឌលវិភាគគោលនយោបាយ ដែលបានសម្ភាសកម្មករចំនួន ១០១០នាក់ និងការស្ទង់មតិរបស់អង្គការឃែរកម្ពុជាជាមួយស្ត្រីកម្មករចំនួន២៨៦នាក់)

- ៣២% នៃស្ត្រីកម្មករបានឃើញអំពើបៀតបៀនរាងកាយកម្មករស្ត្រីផ្សេងទៀតនៅកន្លែងការងារ
- ៣៦% នៃស្ត្រីកម្មករបានរងអំពើហិង្សាពីដៃគូស្និទ្ធស្នាល
- ការទទួលបានប្រាក់ឈ្នួលមិនស្មើគ្នារវាងបុរស ($៨.៣៤/ថ្ងៃ) និងស្ត្រី ($៥.៥៤/ថ្ងៃ)
- មិនទទួលបានច្បាប់សម្រាក និងប្រាក់ឈ្នួលពេលសម្រាកលំហែមាតុភាព
- បង្គន់អនាម័យមិនគ្រប់គ្រាន់សម្រាប់កម្មករ និងគ្មានការបែងចែករវាងបុរស និងស្ត្រី
- មានតែ១១% នៃកម្មករទេដែលមានកិច្ចសន្យាជាលាយលក្ខអក្សរ
- ៩១% នៃកម្មករមិនមានចុះបញ្ជីបេឡាសន្តិសុខសង្គម
- ១៩% រងគ្រោះថ្នាក់នៅកន្លែងការងារ
- ៧៦% នៃកម្មករដែលស្នាក់នៅក្នុងការដ្ឋានសាងសង់ ដែលមិនមានសុវត្ថិភាព

• កន្លែងស្នាក់នៅរបស់កម្មករមានការប្រើប្រាស់គ្រឿងញៀន និងល្បែងស៊ីសង

• ៤៨% នៃកម្មករមានជាប់បំណុល ដែលជាមធ្យមចំនួន $១,៦៤៥ ហើយដែលជាកម្ចីពីធនាគារ ៤២% និងពីមីក្រូហិរញ្ញវត្ថុ ៣៣%

កសិករខ្នាតតូច៖

• ប្រជាកសិករព្រួយបារម្ភពីលទ្ធភាពសងបំណុលទៅស្ថាប័នមីក្រូហិរញ្ញវត្ថុ ដោយសារប្រាក់ចំណូលត្រូវបានថយចុះ ហើយសមាជិកគ្រួសារក៏បាត់បង់ការងារដោយសារវិបត្តិកូវីដទៀត។

• កសិករបន្តរងគ្រោះដោយសារជម្លោះដីធ្លីអូសបន្លាយ មិនទាន់ទទួលបានដំណោះស្រាយ ថែមទាំងបន្តរងគ្រោះពីការបណ្តេញចេញពីលំនៅដ្ឋាន និងត្រូវបានប្តឹងដោយប្រើប្រព័ន្ធតុលាការដោយសារតែការពារដីរបស់ខ្លួន។

• ដោយសារជម្លោះដីធ្លី ដីស្រែចំការត្រូវបានបង្កកចោលរាប់ឆ្នាំធ្វើឱ្យកសិករមិនអាចបង្កបង្កើនផលបានដែលធ្វើឱ្យប៉ះពាល់ដល់សន្តិសុខស្បៀងរបស់កសិករ ក៏ដូចជាការរីកចម្រើននៃវិស័យកសិកម្មនៅកម្ពុជាផងដែរ។

• នៅក្នុងនិយមន័យពាក្យ «ក្រុមស្វ័យនិយោជ» នៅក្នុងច្បាប់ស្តីពីកិច្ចគាំពារសង្គម នៅមិនទាន់មានការពន្យល់ជាក់លាក់ថាតើកសិករជាក្រុមដែលមានចែងនៅក្នុងនិយមន័យនោះដែរ ឬ យ៉ាងណា។